រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

៣.១០.២៣

លេខ :៤២៩២ សសរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារតាមដានការដោះស្រាយសំណើ សំណូមពរ និងមតិយោបល់ របស់មហាជនក្នុងទំព័រហ្វេសប៊ុក (Facebook Page) សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារតាមដានការដោះស្រាយសំណើ សំណូមពរ និងមតិយោបល់របស់មហាជនក្នុងទំព័រហ្វេសប៊ុក (Facebook Page) របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ហៅកាត់ថា «**ក្រុមការងារហ្វេសប៊ុកសម្តេចក្រឡាហោម ស ខេង**» ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម នាយឧត្តមសេនីយ៍ **ជា សុគន្ធា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា នាយករងខុទ្ទកាល័យសម្តេចក្រឡាហោម ប្រធាន

២- ឯកឧត្តម នាយឧត្តមសេនីយ៍ **កែវ ចណ្ណាផុន** អគ្គនាយករងអន្តោប្រវេសន៍ អនុប្រធាន

៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ណាយ គឹមឡឿន** អគ្គស្នងការរងនគរបាលជាតិ អនុប្រធាន

៤- ឯកឧត្តម **សុស ប្រាជ្ញា** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល អនុប្រធាន

៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក **គង់ ធីលីន** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន អនុប្រធាន

៦- ឯកឧត្តម ឧត្តមសេនីយ៍ទោ **នូ ចន្ទី** នាយករងខុទ្ទកាល័យសម្តេចក្រឡាហោម និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន អនុប្រធាន

| | | |
|---|---|---|
| ៧- ឯកឧត្តម ឧត្តមសេនីយ៍ទោ **អាត់ មុនី** | ជំនួយការសម្តេចក្រឡាហោម និងជា អគ្គនាយករងភស្តុភារ និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៨- ឯកឧត្តម ឧត្តមសេនីយ៍ឯក **កុសល្យ តិរម្យ** | អគ្គនាយករងភស្តុភារ និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក **សាយ ម៉េងឈាង** | អគ្គនាយករងអត្តសញ្ញាណកម្ម | អនុប្រធាន |
| ១០- ឯកឧត្តម **ហ៊ីង យុមនា** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម | អនុប្រធាន |
| ១១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈួន សុផេង** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | អនុប្រធាន |
| ១២- ឯកឧត្តម ឧត្តមអគ្គានុរក្ស.១ **សន កែម** | អគ្គនាយករងពន្ធនាគារ | អនុប្រធាន |
| ១៣- ឯកឧត្តម ឧត្តមសេនីយ៍ត្រី **មាន ចន្ថា** | អគ្គនាយករងសវនកម្មផ្ទៃក្នុង | អនុប្រធាន |
| ១៤- លោក **សាយ សុវណ្ណារិទ្ធ** | ជំនួយការសម្តេចក្រឡាហោម និងជា អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ១៥- លោកឧត្តមសេនីយ៍ទោ **អ៊ីម ចាសនា** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ១៦- លោកឧត្តមសេនីយ៍ត្រី **ម៉ិន ខេមរដ្ឋ** | អនុប្រធាននាយកដ្ឋានសរុប-ផែនការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៧- លោកវរសេនីយ៍ឯក **កែ សេរីចន្ទ្រា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល-សរុប នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១៨- លោក **សាន ចំរើន** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល រាជធានី ខណ្ឌ និងខេត្ត | សមាជិក |
| ១៩- លោកវរសេនីយ៍ឯក **ផន កែវកញ្ញា** | នាយការិយាល័យ នៃនាយកដ្ឋានសរុប ផែនការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២០- លោកវរសេនីយ៍ទោ **ម៉ិន ពេជ្រឧត្តម** | នាយការិយាល័យ នៃនាយកដ្ឋាន រដ្ឋបាលទូទៅ សេនាធិការដ្ឋាន | សមាជិក |
| ២១- លោកវរសេនីយ៍ទោ **អេង សំឿន** | នាយរងការិយាល័យផ្សព្វផ្សាយអប់រំ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២២- លោកវរសេនីយ៍ទោ **សោម សុជាតិ** | នាយរងការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល ទូទៅ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២៣- លោកវរសេនីយ៍ត្រី **ម៉ិច សុវណ្ណារ៉ា** | នាយរងការិយាល័យរដ្ឋ-សរុបនៃនាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ២៤- លោកអនុសេនីយ៍ឯក **តី ស៊ង** | នាយផ្នែករដ្ឋបាលការិយាល័យពិធីការ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ២៥- លោកអនុសេនីយ៍ទោ **ទ៉ាន គុណា** | នាយរងផ្នែកភស្តុភារ នៃនាយដ្ឋាន ទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ២៦- លោកអនុសេនីយ៍ត្រី **ឌុង ម៉េងច័ន** | មន្ត្រីនៃអគ្គលេខាធិការដ្ឋាន | សមាជិក |

**ប្រការ២ ._**

ក្រុមការងារនេះមានភារកិច្ច៖

- ទទួលគ្រប់គ្រងការងារបច្ចេកទេស នៃទំព័រហ្វេសប៊ុករបស់ **សម្តេចក្រឡាហោម**
- ផ្សព្វផ្សាយព័ត៌មានតាមបណ្តាញទំនាក់ទំនងសង្គម (ហ្វេសប៊ុក ប្រូសាយ កម្មវិធីវីដេអូសព្វវេ និងបណ្តាញ Online) នូវរាល់សកម្មភាពការងាររបស់ **សម្តេចក្រឡាហោម** ក្នុងបេសកកម្ម បម្រើប្រទេសជាតិ និងប្រជាជន ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

- ដកស្រង់ សំណើ សំណូមពរ និងមតិយោបល់របស់មហាជនពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ក្នុងទំព័រហ្វេសប៊ុក (Facebook Page) **សម្តេចក្រឡាហោម** ដើម្បីគោរពជូន **សម្តេចក្រឡាហោម** ជ្រាប និងពិនិត្យផ្តល់មតិដឹកនាំដ៏ខ្ពង់ខ្ពស់
- បញ្ជូនឯកសារតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** ទៅបណ្តាអគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ រដ្ឋបាលរាជធានី-ខេត្ត ដើម្បីពិនិត្យ និងដោះស្រាយតាមសមត្ថកិច្ច
- តាមដាន និងជម្រុញការដោះស្រាយរាល់សំណើ សំណូមពរ និងមតិយោបល់របស់មហាជន ដែលទទួលបានគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម**
- ទទួលរបាយការណ៍អំពីលទ្ធផល នៃការដោះស្រាយពីបណ្តាអគ្គនាយកដ្ឋាន ឬអង្គភាពពាក់ព័ន្ធ និងរដ្ឋបាលរាជធានី-ខេត្ត ដើម្បីគោរពជូន **សម្តេចក្រឡាហោម** ជ្រាប និងពិនិត្យផ្តល់មតិដឹកនាំដ៏ខ្ពង់ខ្ពស់
- ឆ្លើយតបលទ្ធផល នៃការដោះស្រាយទៅម្ចាស់គណនីវិញ តាមគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម**
- ក្នុងករណីចាំបាច់ ក្រុមការងារនឹងគោរពស្នើសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** ដើម្បីចុះទៅពិនិត្យដោះស្រាយផ្ទាល់ នូវសំណើ សំណូមពរ និងមតិយោបល់របស់មហាជនដោយសហការជាមួយបណ្តាអគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលរាជធានី-ខេត្ត
- ធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស អឌ្ឍមាស និងឆ្នាំ អំពីលទ្ធផល នៃការដោះស្រាយ ឬមិនទាន់ដោះស្រាយពីបណ្តាអគ្គនាយកដ្ឋាននានា អង្គភាពពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ដើម្បីគោរពជូន **សម្តេចក្រឡាហោម** ជ្រាប ឬពិនិត្យ សម្រេច និងស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ **សម្តេចក្រឡាហោម** ។

**ប្រការ៣ ._**

ប្រធាន និងអនុប្រធានក្រុមការងារអាចចាត់មន្ត្រីក្រោមឱវាទរបស់ខ្លួនឲ្យជួយការងារក្នុងករណីចាំបាច់ ។

**ប្រការ៤ ._**

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥ ._**

នាយកខុទ្ទកាល័យសម្តេចក្រឡាហោម **ស ខេង** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង រដ្ឋបាលរាជធានី-ខេត្ត ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ អង្គារ ៦ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន :</u>

- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ "ដើម្បីជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ